ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៤៨៥ ក្រ១១ "ង"

ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧៧៧១

ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ ៥៦២៦

ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ១៥១៦

ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង១៤និង០០នាទីរសៀល នៅសាលសវនាការទី៩ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រីចៅក្រម [redacted] ប្រធានក្រុមប្រឹក្សា

លោកអនុប្រធាន [redacted] ចៅក្រមប្រឹក្សា

លោកចៅក្រម [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៧៧៧១ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] យីស៊ីង ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិចិន ទីកន្លែងកំណើតនៅភូមិ [redacted] ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ជាទីតិជន ទោសពីមុន គ្មាន។

ឃាត់ខ្លួនថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១២៩៣៦ (គ១) ដ.ឃ.ដ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។

ជាប់ចោទពីបទ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ២B ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោកមេធាវី [redacted] រ៉េ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ វ៉ាង យីស៊ីង។

២-ឈ្មោះ [redacted] ថាវថាវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិចិន មុខរបរជាងភ្លើង ទីកន្លែងកំណើតនៅប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅបន្ទប់ជួល [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជាទីតិជន ទោសពីមុន គ្មាន។

ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ០៩៧ (គ១) ដ.ឃ.ដ ចុះថ្ងៃទី[illegible] ឆ្នាំ២០២១។

ជាប់ចោទពីបទ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ២B ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោកមេធាវី [redacted] ចំរើន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាវថាវ ។

លោក ម៉េង សេង ជាអ្នកបកប្រែភាសាចិនឲ្យជនជាប់ចោទឈ្មោះ [redacted] ឃឺស៊ីង និងឈ្មោះ [redacted] ថាវថាវ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ថាវថាវ បានយកគ្រឿងញៀនចំនួន៣៧កញ្ចប់មកផ្ញើទុកនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ឃឺស៊ីង ដោយបានប្រាប់ថា "ខ្លួននឹងមកយកគ្រឿងញៀននោះវិញនៅរយៈពេលកន្លះខែក្រោយ"។ ក្រោយមកនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ថាវថាវ ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ លុះនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៣និង៣០នាទី ដោយទទួលបានព័ត៌មានពីប្រជាពលរដ្ឋល្អមានការអនុញ្ញាតពីលោកព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងជំនាញការិយាល័យអន្តរាគមន៍នៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះប្រតិបត្តិការបង្ក្រាបជាក់ស្តែងករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចបន្ទប់លេខ២៨ ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ឃឺស៊ីង រួមទាំងវត្ថុតាងជាគ្រឿងញៀនចំនួន៣០៣កញ្ចប់ទម្ងន់៧៩០.៥៧ក្រាម នាំយកមកកាន់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនដើម្បីធ្វើការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់តែម្តង។

**-បានឃើញ**របាយការណ៍សំយោគលេខ១៦៨៧ រ.ប.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀននៃនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌-អគ្គស្នងការដ្ឋាននគរបាលជាតិ។

**-បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៥៧២៦ អ.យ.ង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ**ដីកាសន្និដ្ឋានស្ថាពរលេខ១៣៤១ អ.យ.ង ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ**ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២០៦៤ (គ១) ដ.ដ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឃឺស៊ីង បានឆ្លើយថា៖ សមត្ថកិច្ចបានឃាត់រូបខ្លួនដោយសារខ្លួនពាក់ព័ន្ធក្នុងបទល្មើសរក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ ក្នុងបន្ទប់ជួលលេខ៩២។ ខ្លួនមិនទទួលស្គាល់នូវការចោទប្រកាន់ថាខ្លួនជាអ្នកជួញដូរនិងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនទេ គឺគ្រាន់តែខ្លួនបានប្រើប្រាស់ថ្នាំញៀនប៉ុណ្ណោះ។ ខ្លួនចូលមកប្រទេសកម្ពុជានៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ដើម្បីធ្វើជាអ្នករត់តុនៅក្នុងភោជនីយដ្ឋានសាសៀននៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ គ្រឿងញៀនប្រភេទយ៉ាម៉ាគ្រាប់ (ម៉ាតូ) ដែលសមត្ថកិច្ចចាប់យកមានចំនួន៣៧កញ្ចប់ជាគ្រឿងញៀនដែលឈ្មោះ [redacted] ថាវថាវ បានយកគ្រឿងញៀនប្រភេទយ៉ាម៉ា (ម៉ាតូ) យកមកផ្ញើទុកនៅបន្ទប់ (៩២) របស់ខ្លួន។ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ហើយឈ្មោះ [redacted] ថាវថាវ បានប្រាប់ថា "កន្លះខែក្រោយនឹងមានគេទាក់ទងមកយកគ្រឿងញៀននោះទៅវិញ"។ ក្រោយមកនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ថាវថាវ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ លុះប្រហែលនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ មានស្ត្រីជនជាតិចិនម្នាក់បានទាក់ទងមកដើម្បីមកយកគ្រឿងញៀន តែពុំបានឃើញស្ត្រីនោះមកយកគ្រឿងញៀនទេ ហើយខ្លួនក៏បានទុកគ្រឿងញៀននោះរហូតទល់ពេលសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ពេលខ្លួនពុំដែលឃើញស្ត្រីជនជាតិចិនដែលថា "បម្រុងនឹងមកយកគ្រឿងញៀននោះទៅវិញ"។ ខ្លួនក៏បានយកគ្រឿងញៀនមួយកញ្ចប់យកមកប្រើប្រាស់ម្តងៗប្រហែលពីរទៅបីគ្រាប់ជារៀងរាល់ថ្ងៃ រហូតអស់មួយកញ្ចប់នោះដែលមាន

[illegible]

ប្រហែល២០០គ្រាប់។ លុះនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជាងមួយរសៀល សមត្ថកិច្ចបានចូលមកដល់បន្ទប់របស់ខ្លួនស្ថិតនៅបន្ទប់លេខ២២ ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងបានឆែកឆេរចាប់យកគ្រឿងញៀនប្រភេទគ្រាប់ (ម៉ាតូ) ជាច្រើនកញ្ចប់ (៣៧កញ្ចប់) រួចបាននាំពួកខ្លួនមកកាន់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនដើម្បីចាត់ការតាមនីតិវិធី។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនក្នុងខែសីហា ឆ្នាំ២០២០ តាមរយៈឈ្មោះ [redacted] ថាវថាវ អ្នកផ្តល់គ្រឿងញៀនម្តងពីរគ្រាប់ៗសម្រាប់ជក់ និងមានពេលខ្លះជក់គ្រឿងញៀនប្រភេទម៉ាទឹកកក មានពេលខ្លះប្រពន្ធរបស់ខ្លួនជាអ្នកទៅទិញយកមកប្រើនៅក្នុងបន្ទប់២២តែម្តង។ ខ្លួនស្គាល់ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ កាលពីខែកក្កដា ឆ្នាំ២០១៩ នៅប៉ោយប៉ែត និងមានទំនាក់ទំនងគ្នាតាមរយៈការឆាតជាមួយគ្នា។

-ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានឆ្លើយថា៖ ចំពោះអង្គហេតុប្រព្រឹត្តនៅភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ និងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ នោះគឺខ្លួនពុំបានដឹងទេ ខ្លួនសុំបដិសេធចោល។ ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ខ្លួនមិនស្គាល់ទេ។ ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ឆ្លើយថាខ្លួនឱ្យថ្នាំញៀនទៅគាត់ចំនួន៣៧កញ្ចប់ ដើម្បីយកទៅបែងចែកលក់បន្តឱ្យទៅអ្នកផ្សេងនោះ គឺខ្លួនមិនបានដឹងទេ។ ខ្លួនត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ នៅព្រលានយន្តហោះមានការពាក់ព័ន្ធនឹងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រភេទម៉ាទឹកកក ម្សៅខេ និងទឹកសប្បាយសរុបចំនួន១.៥គីឡូក្រាម។ ខ្លួនមិនបានយកថ្នាំញៀនទៅទុកនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ឃីស៊ីង នោះទេ។ ខ្លួនបានចូលមករស់នៅក្នុងប្រទេសកម្ពុជាជិតមួយឆ្នាំមកហើយ ក៏ត្រូវបានចាប់ខ្លួនតែម្តង។ ខ្លួនមានមុខរបរជាបុគ្គលិកល្បែងអនឡាញដែលមានប្រាក់ខែ១.០០០ (មួយពាន់) ដុល្លារអាមេរិកជាង ។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ២៦៨១៥/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបញ្ជាក់ថា៖ វិជ្ជមាន (មានសារធាតុញៀនឈ្មោះមេតំហ្វេតាមីនមានបរិមាណសារធាតុគិតជាភាគរយនៃទម្ងន់សរុបគឺ ៦.០០%) ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ផ្អែកតាមអង្គសវនាការនេះឃើញថា៖ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានយកគ្រឿងញៀនចំនួន៣៧កញ្ចប់មកផ្ញើទុកនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ឃីស៊ីង ដោយបានប្រាប់ថា "ខ្លួននឹងមកយកគ្រឿងញៀននោះវិញនៅរយៈពេលកន្លះខែក្រោយ" ។ ក្រោយមកនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ថាវថាវ ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ លុះនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៣និង៣០នាទី កម្លាំងជំនាញការិយាល័យអន្តរាគមន៍នៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះប្រតិបត្តិការបង្ក្រាបជាក់ស្តែងករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចបន្ទប់លេខ២៦ ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង រួមទាំងវត្ថុតាងជាគ្រឿងញៀនចំនួន០៣កញ្ចប់ទម្ងន់៧៩០.៥៧ក្រាម ប្រាកដមែន។ ហេតុនេះតំណាងអយ្យការប្តឹងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ១៣៥១ អ.យ.ង ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការពិចារណា និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី [redacted] វ៉ៃ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង បានធ្វើសេចក្តីសន្និដ្ឋានថា៖ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានយកគ្រឿងញៀនចំនួន៣៧កញ្ចប់មកផ្ញើទុកនៅក្នុងបន្ទប់របស់កូនក្តីខ្លួន ដោយបានប្រាប់ថា "ខ្លួននឹងមកយកគ្រឿងញៀននោះវិញនៅរយៈពេលកន្លះខែក្រោយ"។ ក្រោយមកនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ថាវថាវ ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

លុះនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៣និង៣០នាទី កម្លាំងជំនាញការិយាល័យអន្តរាគមន៍នៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះប្រតិបត្តិការបង្ក្រាបជាក់ស្តែងករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចបន្ទប់លេខ២៦ ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនកូនក្តីខ្លួនរួមទាំងវត្ថុតាងជាគ្រឿងញៀនចំនួន០៣កញ្ចប់ទម្ងន់៧៩០.៥៧ក្រាម។ កូនក្តីខ្លួនក៏បានសារភាពនូវកំហុសរបស់ខ្លួនថាបានប្រព្រឹត្តអំពើរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។ ផ្អែកតាមលទ្ធផលកោសលវិច័យបានបញ្ជាក់ថាវិជ្ជមាន និងមានកម្រិតភាពសុទ្ធ ៦% នៃទម្ងន់សរុប ។ ថ្នាំញៀននេះ មានកម្រិតទាបនិងមិនបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរនោះទេ។ ហេតុនេះ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះ។

-លោកមេធាវី [redacted] ចំរើន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង បានឆ្លើយដាក់បន្ទុកមកលើកូនក្តីខ្លួន។ ម្យ៉ាងវិញទៀតពុំមានភាពដាច់ខាតថាកូនក្តីខ្លួន និងជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង បានស្គាល់គ្នានោះទេ។ ការសន្និដ្ឋានថាកូនក្តីខ្លួនបានស្គាល់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង មានលើសពីវិមតិសង្ស័យនោះទេ។ ពុំមានភស្តុតាងសម្រាប់ដាក់បន្ទុកមកលើកូនក្តីខ្លួនថាបានជួញដូរ រក្សាទុក និងប្រើប្រាស់គ្រឿងញៀននោះទេ និងពុំមានភស្តុតាងដើម្បីបញ្ជាក់ថា កូនក្តីខ្លួនមានទំនាក់ទំនងស្គាល់គ្នាជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ផងដែរ។ ហេតុនេះ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់នេះដោយក្តីអនុគ្រោះផង។

## **<u>សម្តីចុងក្រោយរបស់ជនជាប់ចោទ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីការចោទប្រកាន់ផង។

-ក្រោយពីបានសួរដេញដោលក្នុងអង្គសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **<u>សំអាងហេតុ</u>**

១-តាមលទ្ធផលនៃការគណនាអំពីវត្ថុចាប់យកជាក្រាមពណ៌សថ្លារបស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង និងឈ្មោះ [redacted] ថាវថាវ មានទម្ងន់៧៩០.៥៧ក្រាម x ៦% ស្មើនឹង ៤៧.៤៣ ក្រាម។ តាមលទ្ធផលនេះ គឺវាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដែលមានចែងក្នុងមាត្រា៤០ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានឆ្លើយបដិសេធថា៖ ចំពោះអង្គហេតុប្រព្រឹត្តនៅភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ និងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ នោះគាត់ខ្លួនពុំបានដឹងទេ ខ្លួនសុំបដិសេធចោល។ ខ្លួនមិនស្គាល់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ទេ។ ជនជាប់ចោទឈ្មោះ ភាង ឃីស៊ីង

ឆ្លើយថាខ្លួនឱ្យថ្នាំញៀនទៅគាត់ចំនួនពាលកញ្ចប់ ដើម្បីយកទៅបែងចែកលក់បន្តឱ្យទៅអ្នកផ្សេងនោះ គឺខ្លួនមិនបានដឹងទេ។ ខ្លួនត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ នៅព្រលានយន្តហោះមានការពាក់ព័ន្ធនឹងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រភេទម៉ាទឹកកក ម្សៅខេ និងទឹកសប្បាយសរុបចំនួន១.៥គីឡូក្រាម។ ខ្លួនមិនបានយកថ្នាំញៀនទៅទុកនៅក្នុងបន្ទប់របស់ឈ្មោះ [redacted] ឃីស៊ីង នោះទេ។ ខ្លួនបានចូលមករស់នៅក្នុងប្រទេសកម្ពុជាជិតមួយឆ្នាំមកហើយ ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ខ្លួនមានមុខរបរជាបុគ្គលិកល្បែងអនឡាញដែលមានប្រាក់ខែ១.០០០ (មួយពាន់) ដុល្លារអាមេរិកជាង។

ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានឆ្លើយនោះ មានភាពផ្ទុយគ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ព្រមទាំងភស្តុតាងជារូបថតដែលបានបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] ថាវថាវ ដែលកន្លងមកធ្លាប់បានថតរូបជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ។

ម្យ៉ាងវិញទៀត ជនជាប់ចោទឈ្មោះ [redacted] ថាវថាវ ពុំមានភស្តុតាងណាមួយមកបញ្ជាក់ឱ្យតុលាការជឿបានថា ជនជាប់ចោទពុំមានការពាក់ព័ន្ធនឹងការជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ នោះទេ។

នេះសរបញ្ជាក់ឱ្យតុលាការឃើញថា៖ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ នៅបន្ទប់លេខ៩២ ផ្លូវលំ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ ហ៊ួរ ថាវថាវ ពិតជាបានយកគ្រឿងញៀនទម្ងន់៧៩០.៥៧ក្រាម មកឱ្យជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង ដើម្បីរក្សាទុកលក់ឱ្យស្ត្រីជនជាតិចិន។ លុះនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ពុំឃើញមានស្ត្រីជនជាតិចិនទាក់ទងយកគ្រឿងញៀននោះ ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង បានយកគ្រឿងញៀនមួយកញ្ចប់យកមកប្រើប្រាស់ជារៀងរាល់ថ្ងៃរហូតអស់មួយកញ្ចប់នោះដែលមានប្រហែល២០០គ្រាប់។ លុះនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជាងមួយរសៀល ទើបសមត្ថកិច្ចបានចូលមកដល់បន្ទប់របស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង និងបានឆែកឆេរចាប់យកគ្រឿងញៀនប្រភេទគ្រាប់ (ម៉ាតូ) ចំនួនពាលកញ្ចប់។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង និងឈ្មោះ [redacted] ថាវថាវ បានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោស តាមមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង និងឈ្មោះ [redacted] ថាវថាវ បានបង្ហាញឱ្យឃើញថាជនជាប់ចោទមានចេតនាទុច្ចរិតបង្កឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងនីត្យានុកូលភាពសង្គមដែលមានចែងក្នុងមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង និងឈ្មោះ [redacted] ថាវថាវ បានបង្ហាញឱ្យឃើញថាជនជាប់ចោទមានចេតនាទុច្ចរិតបង្កឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងនីត្យានុកូលភាពសង្គម ដែលមានចែងក្នុងមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង និងឈ្មោះ [redacted] ថាវថាវ ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្ត ជនជាប់ចោទាំងពីរនាក់នេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនជាធរមាន។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានប្តឹងសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ភឹង ឃីស៊ីង និងឈ្មោះ [redacted] ថាវថាវ តាមច្បាប់នោះ។ ការប្តឹងសុំនេះ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៨-លោកមេធាវី [redacted] វែ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង បានធ្វើសេចក្តីសន្និដ្ឋានថា៖ ជូ

សំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះ។ ការសន្និដ្ឋាននេះ គប្បីតុលាការលើកយកមកធ្វើការពិចារណា។

៩-លោកមេធាវី [redacted] ចំរើន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថាវថាវ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់នេះ ដោយក្តីអនុគ្រោះផង។ ការសន្និដ្ឋានសុំនេះ គប្បីតុលាការលើកយកមកធ្វើការពិចារណា។

១០-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឃើស៊ីង ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] ថាវថាវ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិចិន ពីបទ ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ២B ផ្ទះល្វែង ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-ជនជាប់ចោទឈ្មោះ [redacted] ឃើស៊ីង បានសារភាពនូវកំហុសរបស់ខ្លួន សហការជាមួយសមត្ថកិច្ចក្នុងការស៊ើបអង្កេត និងស៊ើបសួរ និងមិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសពីមុនមកទេ។ ហេតុនេះ គប្បីតុលាការលើកយកចំណុចនេះមកធ្វើការពិចារណាក្នុងសម្រេចពីស្ថានសម្រាលដល់ជនជាប់ចោទរូបនេះផងដែរ។

១២-វត្ថុចាប់យកមានក្រាមពណ៌សថ្លាមានទម្ងន់៧៩០.៥៧ក្រាម ដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៣៧០០ វ.វ.ត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ (ក្រោយសល់ពីដកសំណាក),ប័ណ្ណការងាររបស់ឈ្មោះ វ៉ាង ឃើស៊ីង (WANG KEXING) ផ្តល់ដោយក្រសួងការងារ (ប្រទេសកម្ពុជា), ទូរសព្ទដៃម៉ាក Iphone បែកអេក្រង់ចំនួន០១ (មិនដំណើរការ), ប័ណ្ណឥណទានចំនួន០៥ និងលិខិតឆ្លងដែនលេខ EE៩៦៦៦១៥២ របស់ឈ្មោះ [redacted] ឃើស៊ីង ចំនួន០១ក្បាល។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ឃើស៊ីង ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល** ពីបទ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ២B ផ្ទះល្វែង ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ថាវថាវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន)** ពីបទ **ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ២B ផ្ទះល្វែង ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-<u>វត្ថុចាប់យកមាន</u>៖

៣.១-ថ្នាំញៀនក្រាមពណ៌សថ្លាមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៣៧០០ វ.វ.ត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ (ក្រោយសល់ពីដកសំណាក) ត្រូវរឹបអូស និងបំផ្លាញចោល។

៣.២-ប័ណ្ណការងាររបស់ឈ្មោះ វ៉ាង ឃើស៊ីង (WANG KEXING) ផ្តល់ដោយក្រសួងការងារ (ប្រទេសកម្ពុជា), ទូរសព្ទ

ដៃម៉ាក Iphone បែកអេក្រង់ចំនួន០១ (មិនដំណើរការ),ប័ណ្ណឥណទានចំនួន០៥ និងលិខិតឆ្លងដែនលេខ EE៩០០០១៥២ របស់ឈ្មោះ វ៉ាង ឃីស៊ីង ចំនួន០១ក្បាល ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឃីស៊ីង, ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ថាវថាវ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១។ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ១១ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

| ក្រឡាបញ្ជីសវនាការ |ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១១ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

| បានឃើញ<br>ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ក្រឡាបញ្ជី |
|---|---|
| [redacted] | [redacted] |